ជំរឿនប្រជាជន CALIFORNIA ALL 2020



## អ្វីដែលដែលត្រូវការដឹងអំពីជំរឿននេះ

រៀងរាល់ 10 ឆ្នាំម្តង ពលរដ្ឋនៅទូទាំងប្រទេស និងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ត្រូវបំពេញបែបបទធ្វើជំរឿនដើម្បីទទួលបាននូវការរាប់ចំនួនពលរដ្ឋទាំងអស់នៅក្នុងសហរដ្ឋអាមេរិក ឲ្យបានត្រឹមត្រូវ។ ជំរឿននេះ កំណត់លើការផ្តល់មូលនិធិសហព័ន្ធប្រចាំរដ្ឋកាលីហ្វ័រញ៉ា សម្រាប់សេវាសហគមន៍សំខាន់ៗដែលជួយគាំទ្រដល់ក្រុមគ្រួសាររបស់យើង និងទទួលបានការធ្វើជាតំណាងប្រកបដោយយុត្តិធម៌នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា និងទីក្រុងវ៉ាស៊ីនតោន ឌីស៊ី។

ជំរឿនបន្ទាប់នឹងប្រព្រឹត្តទៅនារដូវផ្ការីក ឆ្នាំ2020។ សូមធានាថា ពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ត្រូវបានគេរាប់ចំនួន ដូចនេះយើងអាចដាក់ធនធានទាំងនោះសម្រាប់ការប្រើប្រាស់ឲ្យបានត្រឹមត្រូវនៅទីនេះ នៅរដ្ឋរបស់យើង!

## កាលបរិច្ឆេទធ្វើជំរឿនសំខាន់ៗ

ចាប់ផ្តើមពីពាក់កណ្តាលខែមីនា ឆ្នាំ2020 គ្រួសារនីមួយ នឹងទទួលបានលិខិតមួយច្បាប់តាមប្រៃសណីយ៍។ លិខិតនោះពន្យល់ពីរបៀបខុសៗគ្នាដែលអ្នកអាចបំពេញបែបបទជំរឿននោះបាន។ ប្រសិនបើអ្នកពុំទទួលបានលិខិតណាមួយទេ អ្នកនៅបន្តអាចចូលទៅកាន់ប្រព័ន្ធអនឡាញ ឬទូរសព្ទដើម្បីធ្វើការបំពេញវាបាន។ ត្រូវប្រាកដថា អ្នករាប់បញ្ចូលនូវបុគ្គលណាម្នាក់ដែលកំពុងរស់នៅក្នុងគ្រួសាររបស់អ្នក ទោះបីជាសមាជិកគ្រួសារឬមិនមែនក៏ដោយ។

- ថ្ងៃទី12 ខែមីនា ឆ្នាំ2020 — លិខិតអញ្ជើញសម្រាប់ជំរឿនឆ្នាំ2020 នឹងត្រូវបានផ្ញើតាមសំបុត្រប្រៃសណីយ៍
- ថ្ងៃទី16 ខែមីនា ឆ្នាំ2024 — លិខិតក្រើនរំឭក ត្រូវប្រគល់ជូនតាមប្រៃសណីយ៍
- ថ្ងៃទី26 ខែមីនា–ថ្ងៃទី3 ខែមេសា — កាតប៉ុស្តាល់ក្រើនរំឭក ត្រូវប្រគល់ជូនតាមប្រៃសណីយ៍
- ថ្ងៃទី1 ខែមេសា — ថ្ងៃធ្វើជំរឿន!
- ថ្ងៃទី8 -16 ខែមេសា — លិខិតក្រើនរំឭកលើកទីពីរ និងឯកសារជំរឿនជាឯកសារក្រដាស នឹងត្រូវប្រគល់ជូនតាមប្រៃសណីយ៍
- ថ្ងៃទី20-27 ខែមេសា — កាតប៉ុស្តាល់ចុងក្រោយ ត្រូវប្រគល់ជូនមុនពេលចុះធ្វើការតាមដានដោយផ្ទាល់

# ហេតុអ្វីបានជាពល
# រដ្ឋកាលីហ្វ័រញ៉ាត
# គប្បីត្រូវធ្វើជំរឿន

ការធ្វើជំរឿននេះ គឺមានសុវត្ថិភាព ទទួលបានការការពារ និងមានលក្ខណៈសម្ងាត់។ ការធ្វើជំរឿនប្រជាជន ជួយដល់ការកំណត់ពីចំនួនទឹកប្រាក់ប៉ុន្មានដែលរដ្ឋកាលីហ្វ័រញ៉ាទទួលបានសម្រាប់កម្មវិធីនិងសេវាកម្មសំខាន់ៗ។ នៅពេលអ្នកបំពេញការធ្វើជំរឿននេះ អ្នកជួយដល់សហគមន៍របស់អ្នកឲ្យទទួលបាននូវទឹកប្រាក់ដែលត្រឹមត្រូវនិងយុត្តិធម៌។

- សាងសង់ផ្លូវថ្នល់ និងសាលារៀនឲ្យបានល្អប្រសើរ
- ផ្តល់មូលនិធិដល់កម្មវិធីសហគមន៍សម្រាប់មនុស្សចាស់ កុមារ និងក្រុមគ្រួសារនានា
- បង្កើតការងារធ្វើ
- កែលម្អលំនៅដ្ឋាន

ព័ត៌មានដែលប្រមូលបានជាផ្នែកមួយនៃជំរឿនឆ្នាំ2020 មិនអាចធ្វើការផ្សព្វផ្សាយដោយភ្នាក់ងាររដ្ឋាភិបាល ឬប្រើប្រាស់ប្រឆាំងលើរូបអ្នកដោយប្រការណាមួយឡើយ។ រដ្ឋកាលីហ្វ័រញ៉ា មានភាពខុសគ្នា និងមានពិពិធភាពច្រើន។ ពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ត្រូវបានរាប់ចំនួន។ ធ្វើជំរឿន

# របៀបបំពេញ

បុគ្គលគ្រប់រូបនៅក្នុងប្រទេសនេះ ត្រូវបានតម្រូវឲ្យបំពេញទម្រង់បែបធ្វើជំរឿនឆ្នាំ2020 នេះ។ ជាសំណាងល្អ អ្នកមានមធ្យោបាយបីយ៉ាងដើម្បីឆ្លើយតប។

---

**តាមប្រៃសណីយ៍៖** ស្នើសុំក្រដាសទម្រង់បែបបទធ្វើជំរឿនជាភាសាអង់គ្លេស ឬភាសាអេស្ប៉ាញតាមប្រៃសណីយ៍ ដែលអាចផ្ញើត្រឡប់ទៅកាន់ក្រសួងជំរឿនប្រជាជនវិញបានតាមប្រៃសណីយ៍។

**តាមទូរសព្ទ៖** ជំរឿនអាចបំពេញបានតាមទូរសព្ទជា 13 ភាសា។

**តាមអនឡាញ៖** ជាលើកទីមួយហើយដែលបែបបទជំរឿននឹងអាចស្វែងរកមកបំពេញនៅតាមអនឡាញជា 13 ភាសា។

---

ខ្សែវីដេអូ និងមគ្គុទេសក៍ដែលបានព្រីនរួច នឹងមានផ្តល់ជូនក្នុងភាសាចំនួន 59 ភាសាក្រៅពីភាសាអង់គ្លេស ហើយនឹងមានវីដេអូជាភាសាសញ្ញាអាមេរិក រួមជាមួយនឹងមគ្គុទេសក៍ណែនាំដែលបានព្រីនចេញជាអក្សរស្ទាបផងដែរ។ ទោះអ្នកសម្រេចជ្រើសរើសបែបណាក៏ដោយ សូមប្រាកដថាថាអ្នកបានបំពេញទម្រង់បែបបទនេះ!